# សុន្ទរកថា
# ឯកឧត្តមកិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
# ថ្លែងក្នុងពិធីបិទអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និង លើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩, ភោជនីយដ្ឋានទន្លេបាសាក់ ២

- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ជាទីគោរព*
- *ឯកឧត្តម លោកជំទាវ តំណាងគ្រប់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ និង មន្ទីរមុខងារសាធារណៈគ្រប់រាជធានី ខេត្ត និង*
- *លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ដែលមានវត្តមាននៅថ្ងៃនេះជាទីស្រលាញ់រាប់អាន*

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ និង កិត្តិយសដ៏វិសេសវិសាល ដែលបានចូលរួមក្នុងពិធីបិទអង្គសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និង លើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ។ ជាបឋម ខ្ញុំសូមអរគុណដល់ **ឯកឧត្តម ព្រុំ សុខា** រដ្ឋលេខាធិការប្រចាំការ ដែលបានដឹកនាំអង្គសន្និបាតរយៈពេលមួយថ្ងៃកន្លះប្រកបដោយជោគជ័យ និង បានអានរបាយការណ៍បូកសរុបលទ្ធផលយ៉ាងពិស្តារជូនអង្គសន្និបាតទាំងមូលនាពេលនេះ។

ក្នុងនាមខ្ញុំជាប្រធានស្ថាប័ន និងជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដឹកនាំក្រសួងមុខងារសាធារណៈ ខ្ញុំសូមសម្តែងការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គាធិការ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលបានប្តេជ្ញាចិត្តខ្ពស់ និង ខិតខំប្រឹងប្រែងយកចិត្តទុកដាក់លើការដឹកនាំ គ្រប់គ្រង និង

អភិវឌ្ឍវិស័យមុខងារសាធារណៈ និងការងារកែទម្រង់រដ្ឋបាលសាធារណៈយ៉ាងសកម្ម ប្រកបដោយប្រសិទ្ធភាព។

ក្នុងឱកាសនេះ ខ្ញុំសូមមិនរៀបរាប់ឡើងវិញទេអំពីសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេលកន្លងមកនេះ ព្រោះបើយោងលើរបាយការណ៍នៃអង្គសន្និបាត យើងឃើញថាក្រសួងមុខងារសាធារណៈ ពិតជាបានខិតខំប្រឹងប្រែងនិងសម្រេចបានលទ្ធផលការងារជាច្រើនក្នុងឆ្នាំកន្លងមកនេះ។ ដោយឡែក ផ្អែកលើលទ្ធផលនៃកិច្ចពិភាក្សាតាមក្រុមកាលពីថ្ងៃទី២៦ ខែមីនា ម្សិលមិញនេះ យើងក៏អាចវាយតម្លៃបានដោយច្បាស់លាស់ថា អង្គសន្និបាតបានផ្តល់ការយកចិត្តទុកដាក់ខ្ពស់ចំពោះការលើកកម្ពស់ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន ការពង្រឹងអភិបាលកិច្ចនិងការលើកកម្ពស់សេវាសាធារណៈ ព្រមជាមួយនឹងការគិតគូរដល់ការបង្កើនប្រសិទ្ធភាព ផលិតភាព និងប្រសិទ្ធផលការងាររបស់មន្ត្រីរាជការនិងអង្គភាពសាធារណៈ។ ចំណុចទាំងអស់នេះ គឺពិតណាស់ស្ថិតនៅក្នុងក្របខណ្ឌនៃគោលបំណង យុទ្ធសាស្ត្រ និងសកម្មភាពដែលបានចង្អុលបង្ហាញដោយយុទ្ធសាស្ត្រចតុកោណដំណាក់ទី ៤ របស់រាជរដ្ឋាភិបាល។

ខ្ញុំសូមបញ្ជាក់ដល់អង្គសន្និបាតថា រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៦ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយផ្តោតលើអាទិភាព៤ គឺ៖ **មនុស្ស ផ្លូវ ទឹក ភ្លើង**។ រាជរដ្ឋាភិបាលបានតម្កល់អាទិភាពទី១ ទៅលើ "**មនុស្ស**"។ ចតុកោណទាំងបួននៃយុទ្ធសាស្ត្រនេះមាន៖ (១).ការអភិវឌ្ឍធនធានមនុស្ស (២).ការធ្វើពិពិធកម្មសេដ្ឋកិច្ច (៣).ការអភិវឌ្ឍវិស័យឯកជននិងការងារ និង (៤).ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន។ ចតុកោណនីមួយៗ ត្រូវបានគាំទ្រដោយស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺ "**ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច**" ដែលមានមុំចំនួន៤៖

១).**ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័ន**

**២).ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ**

**៣).ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ និង**

**៤).ការពង្រឹងអភិបាលកិច្ចវិស័យឯកជន**

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា!*

ឈរលើមូលដ្ឋានខាងលើ ក្រសួងមុខងារសាធារណៈ គឺជាសរសរស្តម្ភគន្លឹះមួយ ដើម្បីជំរុញការអនុវត្តស្នូលនៃយុទ្ធសាស្ត្រចតុកោណ ជាពិសេសការទទួលខុសត្រូវលើការអនុវត្តមុំដែលពាក់ព័ន្ធគឺមុំទី១ មុំទី២ និង មុំទី៣។ ក្នុងន័យនេះ អង្គសន្និបាតរបស់យើង ពិតជាបានផ្តល់នូវធាតុចូលដ៏មានសារៈសំខាន់ដល់ក្រសួងមុខងារសាធារណៈ ក្នុងការរៀបចំនិងដាក់ចេញនូវសកម្មភាពជាក់ស្តែងសម្រាប់រយៈពេលខ្លី មធ្យម និងវែង នៅក្នុងការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ ក៏ដូចជាក្នុងការរៀបចំនិងដាក់ឲ្យអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។

ផ្អែកលើលទ្ធផលនៃអង្គសន្និបាតនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល ក្រសួងមុខងារសាធារណៈ ត្រូវកំណត់ទិសដៅការងារជាអាទិភាពសម្រាប់ឆ្នាំ២០១៩និងបណ្តាឆ្នាំខាងមុខ ទាំងសម្រាប់ក្រសួងមុខងារសាធារណៈខ្លួនឯង ទាំងសម្រាប់កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដោយផ្តោតលើសកម្មភាពសំខាន់ៗដូចខាងក្រោម៖

1. ការពង្រឹងមុខងារ ភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ព្រមជាមួយការលើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលអន្តរស្ថាប័នតាមរយៈសកម្មភាពប្រទាក់ក្រឡានិងគាំទ្រគ្នា ពិសេសយន្តការដឹកនាំនិងសម្របសម្រួលការងារកែទម្រង់នៅថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
2. ការពង្រឹងភាពជាអ្នកដឹកនាំ ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ ការរៀបចំនិងអនុវត្តហ្មត់ចត់នូវក្រមប្រតិបត្តិសម្រាប់បំពេញការងារ ក្រមសីលធម៌វិជ្ជាជីវៈ គោលការណ៍វិសមិតភាពមុខងារនិងទំនាស់ផលប្រយោជន៍នៅក្នុងការបំពេញការងាររបស់មន្ត្រីរាជការ
3. ដាក់ចេញនូវវិធានការណ៍ជាក់ស្តែងក្នុងការធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ការផ្ទេរធនធាន និងចែករំលែកបច្ចេកទេស ដល់អង្គភាពរដ្ឋបាលគ្រប់កម្រិតក្រោមឱវាទក្រសួង និងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ទន្ទឹមនឹងការកំណត់ឱ្យបានច្បាស់លាស់នូវគណនេយ្យភាព និងការទទួលខុសត្រូវរបស់អង្គភាពសាធារណៈនិងមន្ត្រីសាធារណៈ
4. ការលើកកម្ពស់គុណាធិបតេយ្យក្នុងការជ្រើសរើស ការតែងតាំង ការតម្លើងថ្នាក់និងឋានន្តរស័ក្តិ និង ការសម្រិតសម្រាំងរកមន្ត្រីមានសមត្ថភាពខ្ពស់និងគុណវុឌ្ឍល្អប្រសើរសម្រាប់ការតែងតាំងមុខតំណែងដឹកនាំនៅក្នុងមុខងារសាធារណៈ ព្រមទាំងការលើកទឹកចិត្តនិងការផ្តល់អត្ថប្រយោជន៍ដល់មន្ត្រីសាធារណៈនិងអង្គភាពសាធារណៈ ការរៀបចំលិខិតបទដ្ឋាននិងក្របខណ្ឌអភិវឌ្ឍន៍មូលធនមនុស្សដែលទាក់ទាញអ្នកមានសមត្ថភាពជំនាញនិងទេពកោសល្យសំដៅពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈ
5. រៀបចំការដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងប្រាក់សោធននិវត្តន៍ជូននិវត្តជននិងអតីតយុទ្ធជន និងរៀបចំបើកផ្តល់តាមប្រព័ន្ធធនាគារក្នុងរយៈពេល២ សប្តាហ៍ម្តង

6. រៀបចំនិងដាក់ឱ្យអនុវត្តជាដំណាក់កាលៗប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មក្នុងវិស័យសាធារណៈ ដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ ព្រមជាមួយការពង្រឹងយន្តការអធិការកិច្ចនិងសវនកម្ម
7. រៀបចំនិងដាក់ឲ្យអនុវត្តច្បាប់ស្តីពីសេវាសាធារណៈ ព្រមជាមួយការជំរុញការរៀបចំការផ្តល់សេវាសាធារណៈជាកញ្ចប់ ការដាក់ឱ្យអនុវត្តយន្តការតាមដាននិងវាយតម្លៃគុណភាពសេវាសាធារណៈ និងការរៀបចំនិងការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា
8. ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដើម្បីលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រងទិន្នន័យមន្ត្រីសាធារណៈ និងការផ្តល់សេវាសាធារណៈ រួមទាំងការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានបច្ចុប្បន្នភាពស្តីពីសេវាសាធារណៈ លិខិតបទដ្ឋានគតិយុត្ត និងឯកសារគោលនយោបាយជាតិ
9. ជំរុញនវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈនិងចលនានៃការប្រឡងប្រណាំងក្នុងការផ្តល់សេវាសាធារណៈ ដើម្បីធានាប្រសិទ្ធភាព ទាំងក្នុងការបំពេញមុខងារ និងទាំងក្នុងការប្រើប្រាស់ធនធាន។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា!*

មុននឹងបញ្ចប់ ខ្ញុំសូមទាញចំណាប់អារម្មណ៍របស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ជ្រាបថា កត្តាជោគជ័យលើការអនុវត្តការងារកំណែទម្រង់រដ្ឋបាលសាធារណៈ គឺមិនមែនទៅលឿនទេ តែត្រូវទៅដំណាលគ្នា និងទាំងអស់គ្នា។ ទស្សនទាននេះ មានន័យថាក្រសួងមុខងារសាធារណៈ/គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មិនមែនត្រឹមតែតាក់តែងរៀបចំកម្មវិធី ឬ សកម្មភាព និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ ហើយធ្វើតែឯងនោះទេ តែត្រូវបង្កើនចំណេះដឹង ចំណេះធ្វើ និងសមត្ថភាពជំនាញដល់អ្នកដឹកនាំនិងអ្នកអនុវត្តនៅតាមគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនការចូលរួម ការគាំទ្រ ការអនុវត្ត ភាពជាម្ចាស់ និងការទទួលខុសត្រូវពិតប្រាកដលើការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលជាស្នូលនៃកំណែទម្រង់អភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះដែរ ក្រសួង ស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវលើការរៀបចំនិងអនុវត្តសកម្មភាពកែទម្រង់តាមរយៈការដាក់បញ្ចូលសកម្មភាពទាំងនេះទៅក្នុងថវិកាកម្មវិធីរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំចាត់តាំងសមាសភាពធនធានមនុស្សសម្រាប់ដឹកនាំ គ្រប់គ្រង និងជំរុញអនុវត្តក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន ព្រមទាំងត្រូវផ្តល់របាយការណ៍អំពីវឌ្ឍនភាពជាទៀងទាត់តាមការកំណត់មកគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល។

ជាថ្មីម្តងទៀត ក្នុងនាមខ្ញុំផ្ទាល់ជាប្រធានស្ថាប័ន ជំនួសមុខឲ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តខ្ពស់របស់ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការគ្រប់ឋានុក្រមទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំចំពោះការចូលរួមចំណែករបស់យើងទាំងអស់គ្នា ក្នុងការអភិវឌ្ឍវិស័យមុខងារសាធារណៈ និងការងារកែទម្រង់រដ្ឋបាលសាធារណៈ ឲ្យសម្រេចបាននូវសមិទ្ធផលជាច្រើនទៀតឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក ទេវតាឆ្នាំចាស់ និងយាងទេវតាឆ្នាំថ្មីនៅថ្ងៃខាងមុខ ជូនពរបវរសួស្តី សិរីមង្គល មានលាភ មានជ័យមហាប្រសើរជូន ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីជាថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការគ្រប់ឋានុក្រមទាំងអស់ឲ្យសម្រេចបានជោគជ័យការងារ មានសុភមង្គលគ្រប់ក្រុមគ្រួសារ និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និង លើកទិសដៅការងារឆ្នាំ២០១៩ ចាប់ពីពេលនេះតទៅ៕**

សូមអរគុណ!